ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# សុន្ទរកថា
# លោកជំទាវ នាង ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងទិវាប្រាក់រៀល អបអរសាទរការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ
# លើកទី៣៧

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧

**សូមគោរព ៖**

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាទីមេត្រី!**

ថ្ងៃនេះ តាងនាម ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ខ្ញុំមានសេចក្ដីសោមនស្សរីករាយជាអនេក ដោយបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ទាំងអស់ ក្នុង "ទិវាប្រាក់រៀល" អបអរសាទរការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ លើកទី៣៧, ២០ មីនា ១៩៨០ - ២០ មីនា ២០១៧។ ទិវានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងរំឭកខួបនៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ព្រមទាំងដើម្បីបង្ហាញវឌ្ឍនភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងវិស័យឯកជនក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាតិរបស់យើង ក្នុងប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាពិសេសបង្ហាញពីស្មារតីគាំទ្រប្រាក់រៀលពីគ្រប់មជ្ឈដ្ឋាន ដូចដែលមានការចូលរួមយ៉ាងច្រើនកុះករក្នុងកម្មវិធីរបស់យើងនាពេលនេះជាភស្តុតាងស្រាប់។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ទាំងអស់ ដែលបានឆ្លៀតពេលវេលាដ៏មានតម្លៃចូលរួមក្នុងទិវាប្រាក់រៀលនាពេលនេះ។ ខ្ញុំសូមអរគុណចំពោះសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាពិសេស ឯកឧត្តម សាកលវិទ្យាធិការ ដែលបានផ្ដល់កិច្ចសហការរៀបចំទិវានេះ ព្រមទាំងសូមអរគុណចំពោះ កាសែតខ្មែរថាមស៍ ជាដៃគូសហការក្នុងយុទ្ធនាការផ្សព្វផ្សាយពីសារៈសំខាន់ប្រាក់រៀល ជាមួយនឹងអត្ថបទវិភាគដ៏ក្បោះក្បាយ, ក្រុមហ៊ុនសែលកាត, ធនាគារឯកទេសវីង និងក្រុមហ៊ុន Tous Les Jours ដែលបានសហការឧបត្ថម្ភ ដើម្បីញ៉ាំងឱ្យទិវានេះប្រព្រឹត្តទៅដោយរលូន អធិកអធម និងកាន់តែមានអត្ថន័យជ្រាលជ្រៅថែមទៀត។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនអង្គពិធីដោយសង្ខេបពីប្រវត្តិនៃការប្រើប្រាស់រូបិយវត្ថុនៅកម្ពុជាដូចតទៅ៖ ការប្រើប្រាស់រូបិយវត្ថុនៅកម្ពុជាមានប្រវត្តិចាប់តាំងពីសតវត្សរ៍ទី១ នៅក្នុងសម័យនគរភ្នំ ឬហ្វូណនមកម៉្លេះ។ តាមរយៈការស្រាវជ្រាវរបស់ធនាគារជាតិនៃកម្ពុជាលើប្រវត្តិរូបិយវត្ថុបានបង្ហាញថា មានភស្តុតាងមួយចំនួនបញ្ជាក់ពីការចរាចរប្រាក់កាសនៅកម្ពុជា ដែលធ្វើពីលោហៈផ្សេងៗដោយមានរូមបញ្ចូលនិមិត្តសញ្ញាសាសនាហិណ្ឌូ និងខ្លះទៀតធ្វើអំពីប្រាក់ មានរូបព្រះអាទិត្យរះ ដែលជានិមិត្តសញ្ញានៃអំណាច។ កាសទាំងនេះត្រូវបានប្រទះឃើញពីកំណាយនៅអង្គរបុរីដែលជារាជធានីក្នុងសម័យនគរភ្នំ។ ទោះជាយ៉ាងណាមិនទាន់មានការសន្និដ្ឋានជាក់លាក់ថា មានការបោះផ្សាយរូបិយវត្ថុខ្មែរនាសម័យនោះនៅឡើយទេ។ រហូតដល់សតវត្សរ៍ទី១៦ ទើបព្រះស្រីជេដ្ឋា ឬស្តេចកន បានបោះប្រាក់កាសដែលឱ្យឈ្មោះថា "ប្រាក់ស្លឹង" ប៉ុន្តែការប្រើប្រាស់រូបិយវត្ថុជាតិនេះមានលក្ខណៈជានិមិត្តរូបជាជាងលក្ខណៈទូលំទូលាយក្នុងសេដ្ឋកិច្ច។ បន្ទាប់មក នៅសតវត្សរ៍ទី១៩ ក្រោមអាណាព្យាបាលបារាំង ធនាគារឥណ្ឌូចិនបានទទួលសិទ្ធិពិសេសក្នុងការបោះផ្សាយរូបិយវត្ថុក្នុងតំបន់ឥណ្ឌូចិន នៅឆ្នាំ១៨៧៥។ ការប្រើប្រាស់កាសនិងក្រដាសប្រាក់បានចាប់ផ្តើមក្នុងសេដ្ឋកិច្ចចាប់ពីពេលនោះមក។ រហូតដល់ឆ្នាំ១៩៤៨ អាណាព្យាបាលបារាំងបានធ្វើកំណែទម្រង់រូបិយវត្ថុក្នុងតំបន់ ដោយបានបង្កើតរដ្ឋសមាគមឥណ្ឌូចិន ដើម្បីផ្តល់សិទ្ធិដល់ប្រទេសក្នុងតំបន់ឥណ្ឌូចិន ចូលរួមក្នុងការសម្រេចចិត្តច្រើនជាងមុនលើផ្នែករូបិយវត្ថុ ប៉ុន្តែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់បារាំង។ តំបន់ឥណ្ឌូចិនត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៥២ ដើម្បីមានវិទ្យាស្ថានបោះផ្សាយនៃរដ្ឋទាំងបីគឺ កម្ពុជា វៀតណាម និងឡាវ និងបានបោះផ្សាយរូបិយវត្ថុឥណ្ឌូចិនសម្រាប់ប្រើប្រាស់ក្នុងប្រទេសទាំងបី។ ឈ្មោះឯកតារូបិយវត្ថុជាតិខ្មែរ "រៀល" ត្រូវបានចាប់បដិសន្ធិឡើងចាប់ពីពេលនោះមកជាមួយនឹងខ្នាតរូបិយវត្ថុពីរទៀត គឺដុងរបស់វៀតណាម និងគីបរបស់ឡាវ នៅលើក្រដាសប្រាក់ឥណ្ឌូចិនតែមួយ។ ក្រោយមក បន្ទាប់ពីទទួលបានឯករាជ្យពីបារាំង ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងនៅចុងឆ្នាំ១៩៥៤ ហើយបានបោះផ្សាយប្រាក់រៀល សម្រាប់ប្រើប្រាស់នៅក្នុងសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ១៩៥៥។ ប៉ុន្តែគួរឱ្យសោកស្តាយ របបប្រល័យពូជសាសន៍ ប៉ុល ពត បានចូលមកដល់នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដែលបានបំផ្លាញចោលប្រព័ន្ធរូបិយវត្ថុនិងហិរញ្ញវត្ថុនិងរាល់ខឿនសេដ្ឋកិច្ចនិងសង្គមទាំងស្រុង។

គួររំឭកថា នៅថ្ងៃនេះកាលពី ៣៧ឆ្នាំមុន ប្រាក់រៀលត្រូវបានដាក់ឱ្យចរាចរឡើងវិញពោលគឺត្រឹមតែរយៈពេល៦ខែប៉ុណ្ណោះ បន្ទាប់ពីធនាគារកណ្តាលត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩។ ក៏ប៉ុន្តែ ការអូសបន្លាយនៃសង្គ្រាមស៊ីវិលជិត ៣០ឆ្នាំ

បានធ្វើឱ្យសាធារណជនបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀល ស្របពេលដែលវត្តមានប្រាក់ដុល្លារអាមេរិកយ៉ាងសន្ធឹកសន្ធាប់បានហូរចូលមកកម្ពុជា តាមរយៈចំណាយលើការរៀបចំការបោះឆ្នោតរបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ក្នុងអំឡុងឆ្នាំ១៩៩២-១៩៩៣។ ទោះជាយ៉ាងនេះក្តី នាពេលបច្ចុប្បន្ន ខ្ញុំពិតជាមានមោទនភាពក្រៃលែងដែលសង្កេតឃើញថា ជំនឿទុកចិត្តលើប្រាក់រៀលត្រូវបានពង្រឹងជាលំដាប់។ ជាក់ស្តែង ការប្រើប្រាស់ប្រាក់រៀលបានកើនឡើងក្នុងអត្រាជាមធ្យមប្រមាណ ១៧% ចំពោះប្រាក់រៀលក្នុងចរាចរណ៍ និង ២៦% ក្នុងប្រព័ន្ធធនាគារ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ខណៈដែលដុល្លារូបនីយកម្មមានសមាមាត្រប្រមាណ ៨៣% ដែលជាកម្រិតមួយថេរចាប់តាំងពីឆ្នាំ២០១២មក។ លើសពីនេះ យោងតាមលទ្ធផលអង្កេតរបស់ធនាគារជាតិនៃកម្ពុជានិងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) លើស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា បង្ហាញថា ប្រាក់រៀលមានវិសាលភាពចរាចរណ៍នៅគ្រប់ទីកន្លែងនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសមានភាពលើសលប់នៅតំបន់ជនបទ ខណៈដែលប្រាក់ដុល្លារអាមេរិកមានវត្តមានច្រើននៅតំបន់ប្រជុំជន ជាពិសេសរាជធានីភ្នំពេញ ប៉ុណ្ណោះ។

ការប្រើប្រាស់ប្រាក់រៀលមានសារៈសំខាន់ណាស់ចំពោះសង្គម និងសេដ្ឋកិច្ចជាតិទាំងមូល។ មុននឹងនិយាយពីសារៈសំខាន់របស់ប្រាក់រៀល ខ្ញុំក៏សូមរំឭកផងដែរពីបទពិសោធន៍ដែលប្រទេសយើងគ្មានរូបិយវត្ថុផ្ទាល់ខ្លួនដើម្បីប្រើប្រាស់កាលពីអតីតកាល។ អវត្តមានរូបិយវត្ថុត្រូវបានមើលឃើញថាជាកត្តាចម្បងមួយក្នុងចំណោមកត្តាសេដ្ឋកិច្ច និងនយោបាយនានា ដែលបានរួមចំណែកក្នុងការធ្វើឱ្យប្រទេសយើងចុះដុនដាបពីស្ថានភាពនៃប្រទេសដែលបានអភិវឌ្ឍខ្លួនក្លាយទៅជាអាណាចក្រខ្មែរក្នុងសម័យអង្គរ។ បទពិសោធន៍នេះបង្ហាញយ៉ាងជាក់ស្បាន់ថា កម្ពុជាត្រូវតែរក្សានិងជំរុញការប្រើប្រាស់ប្រាក់រៀល ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិប្រកបដោយចីរភាព។

រូបិយវត្ថុមានអត្ថន័យនិងគុណតម្លៃសំខាន់ណាស់ចំពោះនយោបាយ និងសង្គម ដោយសារតួនាទីរូបិយវត្ថុជាតំណាងឱ្យអធិបតេយ្យភាពជាតិ វប្បធម៌និងអរិយធម៌ជាតិ ឯករាជ្យភាពជាតិ និងអំណាចសេដ្ឋកិច្ចរបស់រដ្ឋ។ ប្រាក់រៀលតំណាងឱ្យអត្តសញ្ញាណជាតិខ្មែរមួយក្នុងចំណោមអត្តសញ្ញាណនានា។ រូបភាពដែលរំលេចលើក្រដាសប្រាក់ឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រនិងការរីកចម្រើនផ្ទាល់របស់សង្គមជាតិ ហើយការប្រើប្រាស់ប្រាក់រៀលតែមួយនឹងរំឭកនិងជំរុញទឹកចិត្តប្រជាជនខ្មែរគ្រប់រូបឱ្យកាន់តែមានស្មារតីជាតិនិយម និងសាមគ្គីភាពជាតិ។

ចំពោះផ្នែកសេដ្ឋកិច្ច ប្រាក់រៀលពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុនិងគោលនយោបាយអត្រាប្តូរប្រាក់ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ និងស្ថិរភាព

ម៉ាក្រូសេដ្ឋកិច្ចទាំងមូល។ នៅក្នុងវិស័យពាណិជ្ជកម្ម ការប្រើប្រាស់ប្រាក់រៀលតែមួយជួយកាត់បន្ថយចំណាយប្រតិបត្តិការ ដូចជាការប្តូរប្រាក់សម្រាប់ដោះដូរក្នុងស្រុក កាត់បន្ថយហានិភ័យពីការបាត់បង់ដោយសារការប្រែប្រួលអត្រាប្តូរប្រាក់ និងសម្រួលការកំណត់ថ្លៃដោះដូរតែមួយ ដែលធ្វើឱ្យការដោះដូរប្រព្រឹត្តទៅយ៉ាងងាយស្រួលនិងឆាប់រហ័ស។ ការប្រើប្រាស់ប្រាក់រៀលរួមចំណែកជំរុញការវិនិយោគនិងបង្កើតការងារ តាមរយៈឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុ លើការបន្ទាបអត្រាការប្រាក់ទីផ្សារ ដែលជាកត្តាកំណត់និន្នាការនៃកម្ចីសម្រាប់ការវិនិយោគនិងផលិតកម្ម និងឈានទៅជំរុញឱ្យមានការបង្កើតការងារ។ លើសពីនេះ ការប្រើប្រាស់ប្រាក់រៀល នឹងធ្វើឱ្យប្រទេសយើងទទួលបានប្រាក់ចំណូលពីការបោះពុម្ព និងស្រូបយកនូវរូបិយប័ណ្ណ ដើម្បីគរពូនជាទុនបម្រុង សម្រាប់ពង្រឹងជំនឿទុកចិត្តរបស់វិនិយោគិនមកលើសេដ្ឋកិច្ចកម្ពុជា។ សំខាន់ជាងនេះ រាជរដ្ឋាភិបាលអាចអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណចារឹកជាប្រាក់រៀលដ៏រឹងមាំមួយ ដើម្បីគាំទ្រដល់ការផ្តល់ហិរញ្ញប្បទានក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងកាត់បន្ថយបំណុលពីបរទេស តាមរយៈការកៀរគរមូលនិធិពីសាធារណជន។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាទីមេត្រី!**

កំណើនជំនឿទុកចិត្តលើប្រាក់រៀល បានផ្តល់សុទិដ្ឋិនិយមលើការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយបន្ថែមទៀត ជាពិសេសគាំទ្រដោយវត្តមាននៃបុរេលក្ខខណ្ឌចម្បងៗ រួមមាន ទស្សនវិស័យវិជ្ជមានចំពោះកំណើនសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម ជាមួយនឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុយ៉ាងរឹងមាំ។ រាជរដ្ឋាភិបាលនិងធនាគារជាតិនៃកម្ពុជា នឹងបន្តគាំទ្រនិងលើកទឹកចិត្តដល់សាធារណជនទាំងអស់ក្នុងការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដែលផ្តល់ឥណទានជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានកង្វះខាតប្រាក់រៀលក្នុងប្រតិបត្តិការ ដោយមានមូលបត្រអាចជួញដូរបាន (NCDs) របស់ធនាគារជាតិនៃកម្ពុជាជាវត្ថុធានា។ លើសពីនេះ ប្រតិបត្តិការនេះក៏បានចូលរួមចំណែកកាត់បន្ថយអត្រាការប្រាក់ឥណទានជាប្រាក់រៀលផងដែរ។ ចំពោះការផ្តល់ឥណទានរបស់វិស័យធនាគារ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាស ឱ្យបង្កើនការផ្តល់ឥណទានជាប្រាក់រៀលជាលំដាប់ ដល់យ៉ាងតិចបំផុត ១០% នៃសំពៀតឥណទានសរុបនៅចុងឆ្នាំ២០១៩។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងវិស័យសាធារណៈនិងវិស័យឯកជន ដែលបានខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់យើងនារយៈពេលកន្លងមក។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា យើងទាំងអស់គ្នានឹងបន្តចូលរួមចំណែកបន្ថែមទៀតក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែច្រើនឡើងជាលំដាប់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧញ៉ា លោក លោកស្រី ដែលបានអញ្ជើញចូលរួមក្នុងទិវាប្រាក់រៀលរបស់យើងនាពេលនេះនិងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**